**ព្រះរាជាណាចក្រកម្ពុជា**

ជាតិ សាសនា ព្រះមហាក្សត្រ

**ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ**

SOCIAL PROTECTION IN CAMBODIA

# សេចក្តីជូនដំណឹង

## ស្តីពី

## ការបើកផ្តល់ប្រាក់ឧបត្ថម្ភជូនបងប្អូនកម្មករនិយោជិតក្នុងវិស័យកាត់ដេរ ដែលត្រូវបានព្យួរកិច្ចសន្យាការងារស្របតាមស្មារតីនៃកញ្ចប់វិធានការរបស់រាជរដ្ឋាភិបាល (លើកទី៣)

ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ សូមជូនដំណឹងដល់បងប្អូនកម្មករនិយោជិតចំនួន ៦ ៨២៤នាក់ នៃរោងចក្រទាំង២១ នៃវិស័យវាយនភណ្ឌ កាត់ដេរ ផលិតស្បែកជើង និងផលិតផលិតផលធ្វើដំណើរនិងកាបូប (ដូចមានភ្ជាប់នៅក្នុងឧបសម្ព័ន្ធ) ដែលទទួលបានការអនុញ្ញាតព្យួរកិច្ចសន្យាការងារស្របតាមស្មារតីនៃសេចក្តីណែនាំលេខ០២០/២៣ ក.ប/ស.ណ.ន.ខ.ល ចុះថ្ងៃទី១៥ ខែមីនា ឆ្នាំ២០២៣ ស្តីពីការព្យួរកិច្ចសន្យាការងារកម្មករនិយោជិតធ្វើការនៅរោងចក្រក្នុងវិស័យវាយនភណ្ឌ កាត់ដេរ ផលិតស្បែកជើង និងផលិតផលិតផលធ្វើដំណើរនិងកាបូប ដែលរងផលប៉ះពាល់ដោយសារវិបត្តិសេដ្ឋកិច្ចសកល ជ្រាបថា ធនាគារ វីង (ខេមបូឌា) ម.ក នឹងផ្ញើសារអំពីការបើកប្រាក់ឧបត្ថម្ភរបស់រាជរដ្ឋាភិបាលទៅលេខទូរសព្ទដែលបងប្អូនបានផ្តល់មកឱ្យក្រសួងតាមរយៈរដ្ឋបាលរោងចក្រ នាពេលកន្លងមក។

ប្រាក់ឧបត្ថម្ភនេះនឹងត្រូវបើកផ្តល់ជាប្រាក់រៀល និងអាស្រ័យលើចំនួនថ្ងៃនៃការព្យួរកិច្ចសន្យាការងារ ក្នុងនោះចំនួនៈ

- ៨១ ០០០រៀល (២០ដុល្លារអាម៉េរិក) សម្រាប់ការព្យួរកិច្ចសន្យាការងាររយៈពេល ៧ថ្ងៃ ដល់ ១៤ថ្ងៃ
- ១៦២ ០០០រៀល (៤០ដុល្លារអាម៉េរិក) សម្រាប់ការព្យួរកិច្ចសន្យាការងាររយៈពេល ១៥ថ្ងៃ ដល់ ១ខែ។

ក្រសួងសូមរំឭកថា ធនាគារ វីង (ខេមបូឌា) ម.ក នឹងបង្វិលប្រាក់ឧបត្ថម្ភនេះជូនរាជរដ្ឋាភិបាលវិញ ប្រសិនជាបងប្អូនខកខាន មិនបានទៅបើកប្រាក់ឧបត្ថម្ភនេះ ក្នុងរយៈពេល ២១ថ្ងៃ បន្ទាប់ពីទទួលបានសារតាមទូរសព្ទពីធនាគារ វីង (ខេមបូឌា) ម.ក។ ដើម្បីបើកប្រាក់ឧបត្ថម្ភនេះ បងប្អូនត្រូវយកអត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរ និងទូរសព្ទដែលទទួលបានសារនោះទៅកាន់ភ្នាក់ងារវីងដែលនៅជិតបំផុត។ សូមបញ្ជាក់ថា បងប្អូនមិនតម្រូវឱ្យបង់ថ្លៃសេវាទៅភ្នាក់ងារវីងឡើយពេលបើកប្រាក់ឧបត្ថម្ភនេះ។

ក្នុងករណីបងប្អូនកម្មករនិយោជិត ដែលបម្រើការងារនៅរោងចក្រទាំង២១ នេះ មិនបានទទួលសារទូរសព្ទពីធនាគារ វីង (ខេមបូឌា) ម.ក នោះសូមបងប្អូនទំនាក់ទំនងសួរព័ត៌មានបន្ថែម ឬធ្វើបច្ចុប្បន្នភាពលេខទូរសព្ទរបស់ខ្លួនទៅរដ្ឋបាលរោងចក្ររបស់ខ្លួន។ ក្រសួងនឹងបន្តជូនដំណឹងដល់បងប្អូនកម្មករនិយោជិតរោងចក្រដទៃផ្សេងទៀត ដែលទទួលបានការអនុញ្ញាតព្យួរកិច្ចសន្យាការងារអំពីការបើកផ្តល់ប្រាក់ឧបត្ថម្ភនេះ។

អាស្រ័យដូចបានជម្រាបជូនខាងលើ សូម សាធារណជន ជាពិសេសបងប្អូនកម្មករនិយោជិតជ្រាបជាព័ត៌មាន និងសូមរួសរាន់ទំនាក់ទំនងបើកប្រាក់ឧបត្ថម្ភនេះនៅតាមភ្នាក់ងារវីងនានាដែលនៅជិតបំផុតឱ្យបានទាន់ពេលវេលា។

ថ្ងៃ ពុធ ១០កើត ខែ បឋមាសាឍ ឆ្នាំថោះ បញ្ចស័ក ព.ស.២៥៦៧

រាជធានីភ្នំពេញ ថ្ងៃទី ១២ ខែ កក្កដា ឆ្នាំ២០២៣

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ**
**គណៈកម្មការអនុវត្តវិធានការរាជរដ្ឋាភិបាល**

**ឧបសម្ព័ន្ធ នៃសេចក្តីជូនដំណឹងចុះថ្ងៃទី១២ ខែកក្កដា ឆ្នាំ២០២៣**
**បញ្ជីឈ្មោះ រោងចក្រ ក្នុងវិស័យកាត់ដេរ**
**ចំនួន ២១ ដែលទទួលបានប្រាក់ឧបត្ថម្ភរបស់រាជរដ្ឋាភិបាល**

| ល.រ | ឈ្មោះរោងចក្រ | រាជធានី ខេត្ត |
|---|---|---|
| វិស័យកាត់ដេរ | | 21 |
| 1 | ក្រុមហ៊ុន ជេអេដាប់បែលយូ ( J.A.W ) | ភ្នំពេញ |
| 2 | ក្រុមហ៊ុន ហេន7 ហ្វាមិន ឯ.ក | ភ្នំពេញ |
| 3 | ក្រុមហ៊ុន គូម៉ូ អ៉ីភែរឺល ឯ.ក | ភ្នំពេញ |
| 4 | ក្រុមហ៊ុន អ៊ុហ្សី ឡាហ្វ៍ ស៊ូ អិលធីឌី | ភ្នំពេញ |
| 5 | ក្រុមហ៊ុន អ៊ិនហ្វុង (ខេមបូឌា) ហ្វាមិនត៍ | ភ្នំពេញ |
| 6 | ក្រុមហ៊ុន ស៊ីកូ(ភ្នំពេញ)ខូអិលធីឌី | ភ្នំពេញ |
| 7 | ក្រុមហ៊ុន ហុង វ៉ា (កម្ពុជា) ហ្គាមិន ម៉ាញូហ្វាក់ធីរីង លីមីធីត | ភ្នំពេញ |
| 8 | ក្រុមហ៊ុន ម៉ាស្ទេច អ៊ីនខេម (ខេមបូឌា) | ភ្នំពេញ |
| 9 | ក្រុមហ៊ុន ផាយឡឹតនីតស្ពតវែរ (ខេមបូឌា) ខូអិលធីឌី | ភ្នំពេញ |
| 10 | ក្រុមហ៊ុន ស៊ីន ឡាន (ខេមបូឌា)ហ្គាមេន ខមភេនីលីមីធីត | ភ្នំពេញ |
| 11 | ក្រុមហ៊ុន ធី&ខេ ហ្គាមេន អ៊ីនដាស្រ្ទី ខូអិលឌី | ភ្នំពេញ |
| 12 | ក្រុមហ៊ុន ខ្វាន់ទុម ខ្លូស៊ីង (ខេមបូឌា) លីមីតធីត | ភ្នំពេញ |
| 13 | ក្រុមហ៊ុន អ៊ីភីក អ៊ិនធើណេសិនណល ឯ.ក | ភ្នំពេញ |
| 14 | ក្រុមហ៊ុន អ៊ីន ស៊ូ អា អ៉ីភែរឺល | ភ្នំពេញ |
| 15 | ក្រុមហ៊ុន ថបហ្វម (ខេមបូឌា) មេនូហ្វេកឆឺរីង ឯ.ក | កណ្តាល |
| 16 | ក្រុមហ៊ុន មេតថេក (ខេបូឌា) ខប លីមីធីត | កំពង់ចាម |
| 17 | ក្រុមហ៊ុន វ៉ាយស៍ ស៊ីឌី ហ្វូដវែរ មេធៀរៀល (ខេមបូឌា) ឯ.ក | កំពង់ចាម |
| 18 | ក្រុមហ៊ុន សុន ស៊ុយ ស៊ីង អ៊ិនដាសស្រៀល (ខេមបូឌា) ខូអិលធីឌី | កំពង់ស្ពឺ |
| 19 | ក្រុមហ៊ុន ឆាមហ្គោ(ខេមបូឌា)ឯ.ក | កំពង់ស្ពឺ |
| 20 | ក្រុមហ៊ុន អៅដរ ហ្គៀ (ខេមបូឌា) ឯ.ក | តាកែវ |
| 21 | ក្រុមហ៊ុន ធី.ខេ ហ្គាមេន ស៊ីសុផុន | បន្ទាយមានជ័យ |